01031565 E319

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Oct-2014, 13:30
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**(ជាមួយឧបសម្ព័ន្ធសម្ងាត់បំផុតចំនួនពីរ)

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការដាក់បង្ហាញកំណត់ហេតុនៃសំណុំរឿង ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោក Nicholas KOUMJIAN

**ចម្លងជូន:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
Marie GUIRAUD

**ចម្លងជូន:**
ជនជាប់ចោទ
នួន ជា
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSÉ

សហចៅក្រមស៊ើបអង្កេត
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

## I. **ការបង្ហាញ**

១. អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា កាតព្វកិច្ចដើម្បីបង្ហាញសម្ភារៈពាក់ព័ន្ធ ទោះជាដាក់បន្ទុក ឬដោះបន្ទុកក៏ដោយ គឺជាកាតព្វកិច្ចដែលត្រូវធ្លាក់ទៅលើអង្គជំនុំជម្រះសាលាដំបូង ព្រមទាំងជនជាប់ចោទ ដោយហេតុថាវាជា "ប្រយោជន៍ក្នុងការនាំដល់ការស្វែងរកការពិត ដែលអង្គជំនុំជម្រះសាលាមានលទ្ធភាពចូលពិនិត្យមើលឯកសារទាំងនោះបាន"[1]។ ជាងនេះទៅទៀត អង្គជំនុំជម្រះនេះ ពីមុនធ្លាប់សម្រេចថា "វិធាន៥៣(៤) នៃវិធានផ្ទៃក្នុង ដាក់កាតព្វកិច្ចជាបន្តបន្ទាប់ទៅលើសហព្រះរាជអាជ្ញា ដើម្បីបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង នូវសម្ភារៈណាមួយដែលមាននៅក្នុងដៃរបស់ខ្លួន ដែលអាចជាភស្តុតាងបញ្ជាក់ពីភាពគ្មានកំហុស ឬជាការបន្ថយនូវពិរុទ្ធភាពចំពោះជនជាប់ចោទ ឬដែលអាចមានផលប៉ះពាល់ទៅលើភាពជឿទុកចិត្តបាននៃភស្តុតាង"[2]។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យសហព្រះរាជអាជ្ញាថា ជាដំបូងសហព្រះរាជអាជ្ញាត្រូវដាក់សំណើសុំបង្ហាញភស្តុតាងណាមួយដែលខ្លួនចង់បង្ហាញនោះ មកអង្គជំនុំជម្រះដោយផ្ទាល់ រួចហើយទើបអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារនោះ ដែលនឹងត្រូវអនុម័តលើការដាក់បង្ហាញភស្តុតាងតែម្តង[3]។

២. កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីដែលបានកំណត់អំពីវិសាលភាពនៃសំណុំរឿង០០២/០២[4] ។ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបង្គាប់ឲ្យភាគីនានា នៅក្នុងសំណុំរឿង០០២/០២ ដាក់បញ្ជីឈ្មោះសាក្សីនានានៅត្រឹមថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ ដែលក្នុងនោះត្រូវដាក់បញ្ចូលនូវ "លេខយោងឯកសារនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលពាក់ព័ន្ធ"[5] និងនៅត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ដាក់នូវបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាពរួចដែលពួក

[1] ឯកសារ**E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការជូនដំណឹងអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២", ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។

[2] ឯកសារ**E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការជូនដំណឹងអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលនឹងអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២", ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២ ត្រង់ទំព័រទី១។

[3] ឯកសារ**E127/7/1** ព័ត៌មានពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សីសំណុំរឿង០០៣ និងសំណុំរឿង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង ០០២, ចុះថ្ងៃទី១៦ សីហា ២០១៣, កថាខណ្ឌ២។

[4] ឯកសារលេខ **E301/9/1** សេចក្តីសំរេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមនៅក្នុងសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២, ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤។

[5] ឯកសារលេខ **E305** ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤, កថាខណ្ឌទី២ និងទី៧។

គេមានបំណងផ្តល់ជូន នៅក្នុងសំណុំរឿង០០២/០២[6]។ បន្ទាប់ពីការចេញដីកាបង្គាប់ទាំងនេះ សហព្រះរាជអាជ្ញាបានដឹកនាំធ្វើការពិនិត្យឡើងវិញ លើកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានដឹកនាំធ្វើដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ និង០០៤ ដើម្បីកំណត់អត្តសញ្ញាណនៃចម្លើយសាក្សីដែលជាប់ទាក់ទងនឹង ទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តហេតុនៃឧក្រិដ្ឋកម្មនានាដែលត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២រួចហើយ។ កាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") បានស្នើសុំការអនុញ្ញាតពី កសចស ដើម្បីដាក់បង្ហាញនូវគ្រប់កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់ដែលទាក់ទងនឹងសំណុំរឿង០០២/០២ ដែលបានមកពីសំណុំរឿង០០៤ ទៅក្នុងសំណុំរឿង០០២[7] (ការដាក់ឯកសារស្រដៀងគ្នានេះ ត្រូវបានធ្វើឡើងទាក់ទងនឹងសំណុំរឿង០០៣[8])។ ដូចកាលពីលើកមុនដែលសហព្រះរាជអាជ្ញាធ្លាប់បានរៀបរាប់[9] នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (កសចស) បានបដិសេធសំណើទាំងនេះ "នៅដំណាក់កាលនេះ" ក៏ប៉ុន្តែ "នៅតែទទួលយក" សំណើទាំងនេះដដែល[10] ដោយមានការយល់ឃើញថា ការដាក់បង្ហាញឯកសារបែបដូច្នេះនៅពេលនេះ "អាចបណ្តាលឲ្យ មានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ការស៊ើបសួរ" នៅក្នុងសំណុំរឿងនីមួយៗ[11]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់ឃើញថា "ពុំមានកាលបរិច្ឆេទជាក់លាក់ណាមួយត្រូវបានកំណត់សម្រាប់ការចាប់ផ្តើមការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ នៅឡើយទេ"[12] ហើយបានបញ្ជាក់ថា "នៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ការបង្ហាញឯកសារលែងធ្វើឲ្យប៉ះពាល់ដល់ការស៊ើបសួរទៀតហើយនោះ គាត់នឹងអនុញ្ញាតឲ្យ [សហព្រះរាជអាជ្ញាអន្តរជាតិ] ស្នើសុំបញ្ចូលឯកសារទាំងនេះទៅក្នុងសំណុំរឿងលេខ ០០២/០២"[13] ហើយនឹង "ជូនដំណឹងដល់សហព្រះរាជអាជ្ញាភ្លាម នៅពេលត្រូវបំពេញកាតព្វកិច្ច

---

[6] ឯកសារលេខ **E305** ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤, កថាខណ្ឌទី១១ ដល់ទី១៤។

[7] សំណុំរឿង០០៤ -ឯកសារលេខ **D193** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុសម្ភាសន៍សាក្សីក្នុងសំណុំរឿង០០៤ ដែលទាក់ទងនឹងសវនាការជំនុំជម្រះក្តីសំណុំរឿង០០២/០២, ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤។

[8] សំណុំរឿង០០៣ -ឯកសារលេខ **D100** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុសម្ភាសន៍សាក្សីក្នុងសំណុំរឿង០០៣ ដែលទាក់ទងនឹងសវនាការជំនុំជម្រះក្តីសំណុំរឿង០០២/០២, ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៤។

[9] ឯកសារលេខ **E305/13** បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់ពេលសវនាការ អនុលោមតាមវិធាន៨០(៣), ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤, កថាខណ្ឌទី៩ ។

[10] **CF003-D100/1** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំដាក់បង្ហាញបទសម្ភាសន៍នៅក្នុងសំណុំរឿង ០០៣ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២, ចុះថ្ងៃទី៨ ខែឧសភា ២០១៤ ត្រង់កថាខណ្ឌទី១៧។ **CF004-D193/1** សេចក្តីសម្រេចលើសំណើរបស់សហ ព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំដាក់បង្ហាញបទសម្ភាសន៍នៅក្នុងសំណុំរឿង ០០៣ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២, ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៤ ត្រង់កថាខណ្ឌទី១៧។

[11] *ដដែលដូចខាងលើ*។

[12] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី១១ [សេចក្តីសម្រេចទាំងពីរ]។

[13] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី១២ [សេចក្តីសម្រេចទាំងពីរ]។

ទៅតាមសំណើ”[14]។ ពីមុន សហព្រះរាជអាជ្ញាអន្តរជាតិ បានធ្វើ “ការជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងបានបញ្ជាក់ឡើងវិញ អំពីសំណើរបស់ខ្លួនដែលស្នើសុំដាក់បង្ហាញឯកសារ” នៅពេលណាដែលកាលបរិច្ឆេទនៃការជំនុំជម្រះក្តីត្រូវបានកំណត់ពេល[15]។

៣. ថ្ងៃទី១២ ខែកញ្ញា អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចមួយដោយបញ្ជាក់ពីលំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះក្នុងសំណុំរឿង០០២ និងបានជម្រាបជូនភាគីថា វគ្គដំបូងនៃការជំនុំជម្រះ គឺពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ រួមមាន ការប្រព្រឹត្តិចំពោះពុទ្ធសាសនិក និងមន្ទីរសន្តិសុខក្រាំងតាចាន់[16]។ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការ ក្នុងសំណុំរឿង០០២/០២ ដោយកំណត់កាលបរិច្ឆេទសម្រាប់ការផ្តល់សក្ខីកម្ម ចាប់ផ្តើមថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤[17] នេះតទៅ។ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ និង ថ្ងៃទីទី៩ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើជូន កសចស សុំការអនុញ្ញាតបង្ហាញកំណត់ហេតុពីសំណុំរឿង០០៤ ដែលជាប់ទាក់ទងទៅនឹងការជំនុំជម្រះវគ្គដំបូងនេះ[18]។

៤. នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានទទួលសេចក្តីសម្រេចមួយច្បាប់ ធ្វើឡើងដោយ សចសអ ដែលអនុញ្ញាតឲ្យបង្ហាញអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង០០២ ក្រុមមេធាវីការពារក្តី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នូវកំណត់ស្តាប់ចម្លើយសាក្សីចំនួន ២៧នាក់ពីសំណុំរឿង០០៤[19]។ កំណត់ហេតុទាំងនេះត្រូវបានកំណត់អត្តសញ្ញាណជាឯកសារសម្ងាត់បំផុតក្នុងឧសបម្ព័ន្ធ ក ហើយកំណត់ហេតុទាំងនោះសុទ្ធតែជាប់ពាក់ព័ន្ធនឹងវគ្គដំបូងនៃសវនាការក្នុងសំណុំរឿង ០០២/០២[20]។ សេចក្តីសម្រេចរបស់ សចសអ ក្នុងការអនុញ្ញាតឲ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយទាំងនេះ ហើយដែល សចសអ បានណែនាំព្រមទាំងអនុញ្ញាតឲ្យសហព្រះរាជ

---

[14] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី១៣ [សេចក្តីសម្រេចទាំងពីរ]។

[15] **E305/13** បញ្ជីឯកសារសវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤, កថាខណ្ឌ ទី៩។

[16] **E315** សេចក្តីសម្រេចអំពីលំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅក្នុសំណុំរឿង ០០២/០២, ១២ កញ្ញា ២០១៤, កថាខណ្ឌ១៤។

[17] **E316** ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤។

[18] សំណុំរឿង ០០៤-**D193/2** សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញា សុំដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១ នៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។ សំណុំរឿង ០០៤ - **D193/3** សំណើបន្ថែមសុំដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៤ ចូលក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤។

[19] សំណុំរឿង ០០៤-**D193/4** សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញា សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សី សំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងវគ្គទីមួយនៃសវនាការសំណុំរឿង ០០២/០២, ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ (ចាប់ពីនេះតទៅហៅថា “សេចក្តីសម្រេចស្តីពីការដាក់បង្ហាញ”)។

[20] **E315** សេចក្តីសម្រេចអំពីលំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ នៅក្នុសំណុំរឿង ០០២/០២, ១២ កញ្ញា ២០១៤, កថាខណ្ឌ១៤។

អាជ្ញាបង្ហាញជូនតែអង្គជំនុំជម្រះសាលាដំបូងនោះ[21] គឺត្រូវបានដាក់ឯកសារនេះជា សម្ងាត់បំផុត ក្នុងឧបសម្ព័ន្ធ ខ ។ ការដាក់បង្ហាញនូវកំណត់ហេតុទាំងនេះ គឺជាការចាំបាច់ដើម្បីធានា ទាំងចំពោះ អង្គជំនុំជម្រះសាលាដំបូងអាចចូលពិនិត្យមើលព័ត៌មានពាក់ព័ន្ធ ស្តីពីទីតាំងឧក្រិដ្ឋកម្មផង និងធានា ផងដែលដល់ ជនជាប់ចោទ ក៏អាចមានលទ្ធភាពចូលពិនិត្យលើប្រភពជាសក្ខានុពលទាំងអស់អំពី ព័ត៌មានដោះបន្ទុកនានាផង ដែលអាចពាក់ព័ន្ធទៅនឹងបទចោទដែលពួកគាត់កំពុងត្រូវបានចោទ ប្រកាន់។

៥. ការអនុញ្ញាតរបស់ សចសអ ក្នុងការដាក់បង្ហាញឯកសារនេះ បានភ្ជាប់មកនូវការកម្រិត និង កាតព្វកិច្ចមួយចំនួន ហើយ សចសអ បានស្នើអង្គជំនុំជម្រះសាលាដំបូងធានាឲ្យគ្រប់ភាគីទាំងអស់ គោរពឲ្យបានតាមសេចក្តីសម្រេចស្តីពីការបង្ហាញឯកសារនេះ [22]។ ការអនុញ្ញាតរបស់ សចសអ ក្នុងការដាក់បង្ហាញឯកសារបានកម្រិត និងកំណត់កាតព្វកិច្ចមួយចំនួន ដូចខាងក្រោម ៖

ក. ត្រូវចាត់ទុកជាឯកសារសម្ងាត់[23]។

ខ. មិនត្រូវផ្តល់អត្ថបទជាអេឡិចត្រូនិចទៅឲ្យភាគីសហមេធាវីការពារក្តី ឬទៅឲ្យសហមេធាវី នាំមុខឡើយ ផ្ទុយទៅវិញ ពួកគេទាំងនេះអាចទទួលបានអត្ថបទចម្លង នៃឯកសារទាំងនេះ ជាក្រដាសដែលមានដាក់សញ្ញាសំគាល់ និងមានចុះលេខនៅលើនោះ ពីសហព្រះរាជអាជ្ញា ជាជំនួសវិញ[24]។

គ. ការិយាល័យសហព្រះរាជអាជ្ញា ត្រូវរក្សាទុកនូវកំណត់ហេតុមួយជាលាយលក្សណ៍អក្សរ នៃច្បាប់ចម្លងទាំងឡាយដែលបានធ្វើ ហើយភាគីត្រូវបានបង្ហាញជូននូវច្បាប់ចម្លងនីមួយៗ នៅក្នុងលក្ខណៈដែលអាចឲ្យធ្វើការពិនិត្យឡើងវិញបាន បើសិនជាមានការចាំបាច់[25]។

ឃ. ក្រុមមេធាវីការពារក្តី ឬ សហមេធាវីនាំមុខនានា ត្រូវបង្ហាញជូនដល់សមាជិកទាំងឡាយ នៃក្រុមរបស់ខ្លួន តែកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលត្រូវបានឲ្យរក្សាទុកជាផ្លូវការ ដោយអនុលោមតាមវិធាន២២(៥) និង២៣*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង តែប៉ុណ្ណោះបានហើយ [26]។

---

[21] សេចក្តីសម្រេចស្តីពីដាក់ការបង្ហាញ, កថាខណ្ឌ២៨។

[22] សេចក្តីសម្រេចស្តីពីដាក់ការបង្ហាញ, កថាខណ្ឌ២៦។

[23] សេចក្តីសម្រេចស្តីពីដាក់ការបង្ហាញ, កថាខណ្ឌ២៣(ក)។

[24] សេចក្តីសំរេចស្តីពីការដាក់បង្ហាញ, កថាខណ្ឌទី២៣(ខ)-(គ)។

[25] សេចក្តីសំរេចស្តីពីការដាក់បង្ហាញ, កថាខណ្ឌទី២៣(ឃ)។

[26] សេចក្តីសំរេចស្តីពីការដាក់បង្ហាញ, កថាខណ្ឌទី២៣(ង)។

ង. មិនអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តី និងសហមេធាវីនាំមុខទាំងនេះធ្វើការផលិតឡើងវិញថតចម្លង ឬមួយវិញទៀត ធ្វើឯកសារចម្លងពីច្បាប់ដើមដែលបានផ្តល់ឲ្យទៅពួកគេ ក្រៅពីសម្រាប់ប្រើប្រាស់ផ្ទៃក្នុងនូវឯកសារទាំងនេះ ដោយសមាជិកនៃក្រុមរបស់ពួកគេនីមួយៗរៀងខ្លួនដែលត្រូវបានណែនាំ ឬត្រូវបានអនុញ្ញាតឲ្យអាចមានសិទ្ធិចូលពិនិត្យនូវឯកសារសម្ងាត់បានឡើយ[27]។

ច. ក្រុមសហមេធាវីការពារក្តី និងសហមេធាវីនាំមុខទាំងនេះ ត្រូវរក្សាទុកនូវកំណត់ហេតុមួយជាលាយលក្សណ៍ស្តីពីការបញ្ជូនបន្តពីម្នាក់ទៅម្នាក់ នូវច្បាប់ចម្លងនៃឯកសារដែលបានផ្តល់ទៅឲ្យពួកគេ នៅក្នុងលក្ខណៈមួយដែលអាចឲ្យធ្វើការពិនិត្យឡើងវិញបាន បើសិនជាមានការត្រូវការចាំបាច់[28]។

ឆ. ក្នុងករណី បើសិនជាឯកសារទាំងនេះត្រូវបានទទួលយកធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ នោះ ត្រូវតែចាត់ទុកឯកសារទាំងនេះជាការសម្ងាត់[29]។

ជ. មិនអនុញ្ញាតឲ្យធ្វើការការចែកផ្សាយនូវឯកសារណាមួយ ក្នុងចំណោមឯកសារដែលបានដាក់បង្ហាញ ក្រៅពីបុគ្គលដែលត្រូវបានអនុញ្ញាតច្បាស់លាស់ដូចបានបញ្ជាក់នៅក្នុងនេះ[30]។

ឈ. មិនអនុញ្ញាតឲ្យធ្វើការការចែកផ្សាយ នូវឯកសារណាមួយក្នុងចំណោមឯកសារដែលបានដាក់បង្ហាញ ទៅដល់សាធារណជនឡើយ ទោះបីជានៅក្នុងទម្រង់ណាមួយក៏ដោយ ឬតាមរយៈបណ្តាញផ្សព្វផ្សាយពត៌មានអ្វីក៏ដោយ ហើយគោលបំណងនៃការរឹតត្បឹតនេះ ពាក្យ“សាធារណៈជន” គឺបានន័យថា និងរួមបញ្ចូលគ្រប់បុគ្គល, រដ្ឋាភិបាលនានា, អង្គការនានា, ស្ថាប័ននានា, កូនក្តីទាំងអស់, សមាគមនានា, និងក្រុមនានា លើកលែងតែចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង, បុគ្គលិកការិល័យក្រឡាបញ្ជី, សហព្រះរាជអាជ្ញានឹងតំណាងរបស់សហព្រះរាជអាជ្ញា, ជនជាប់ចោទ និងនិយោជិតណាមួយដែលត្រូវបានអនុញ្ញាត្តិជាផ្លូវការស្របតាមវិធាន២២(៥) និងវិធាន២៣*ស្ទួនពីរ*នៃវិធានផ្ទៃក្នុង ដែលបានអនុញ្ញាតឲ្យក្រុមសហមេធាវីការពារក្តី និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិអាចចូលពិនិត្យមើលឯកសារសម្ងាត់បានរៀងៗខ្លួន។ ដោយពុំមានកំណត់ព្រំដែនពាក្យ

---

27 សេចក្តីសំរេចស្តីពីការដាក់បង្ហាញ, កថាខណ្ឌទី២៣(ច)។

28 សេចក្តីសំរេចស្តីពីការដាក់បង្ហាញ, កថាខណ្ឌទី២៣(ឆ)។

29 សេចក្តីសំរេចស្តីពីការដាក់បង្ហាញ, កថាខណ្ឌទី២៣(ជ)។

30 សេចក្តីសំរេចស្តីពីការដាក់បង្ហាញ, កថាខណ្ឌទី២៣(ឈ)។

"សាធារណជន"បានរួមបញ្ចូលផងដែរ នូវសមាជិកគ្រួសារទាំងអស់របស់ជនជាប់ចោទ, មិត្តភក្តិ, និងពួកអ្នកពាក់ព័ន្ធ, ជនសង្ស័យនានា, ក្រុមសហមេធាវីការពារក្តីនានា, ព្រមទាំងរាល់សមាជិកនៃបុគ្គលិករបស់ក្រុមរៀងខ្លួននៅក្នុងសំណុំរឿងដទៃទៀត ឬនៅក្នុងរឿងក្តីផ្សេងទៀតដែលនៅចំពោះមុខ អវតក, បណ្តាញផ្សព្វផ្សាយព័ត៌មាន និង អ្នកសារព័ត៌មាននានា[31]។

ញ. បើមានសមាជិកណាម្នាក់នៃភាគីទាំងអស់ ឬអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២ បានដឹងថាមានសំណៅចម្លងកំណត់ហេតុស្តាប់ចម្លើយដែលមិនមានការអនុញ្ញាត សមាជិករូបនោះត្រូវចាត់រាល់វិធានការជាបន្ទាន់ទាំងអស់ ដើម្បីធានាឲ្យបានថាសំណៅចម្លងនោះត្រូវបានបង្វិលជូនទៅ សចស វិញ[32]។

ដ. បើមានសមាជិកណាម្នាក់នៃភាគីទាំងអស់ ឬអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២ បានដឹងថាមានការបំពានណាមួយលើលក្ខខណ្ឌ និងការកម្រិតទាំងនេះ សមាជិករូបនោះត្រូវរាយការណ៍អំពីការបំពានបែបដូច្នោះ ជូនទៅ សចស [33]; ហើយនិង

ឋ. ការដាក់កម្រិតទាំងនេះគឺកំពុងឋិតនៅជាធរមាន រហូតទាល់តែមានការកែប្រែតាមសេចក្តីបង្គាប់យ៉ាងច្បាស់លាស់អំពីអានុភាពនេះធ្វើឡើងដោយ សចស, ឬមួយក៏ដោយសារការស៊ើបសួរលើសំណុំរឿង ០០៤ ត្រូវបានបិទ[34]។

៦. ពីមុន អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបង្គាប់ថា រាល់ការដាក់បង្ហាញឯកសារទាំងអស់ពីសំណុំរឿង ០០៣ និង ០០៤ ទៅក្នុងសំណុំរឿង ០០២ ត្រូវតែដាក់ និងជូនដំណឹង ជូនទៅអង្គជំនុំជម្រះសាលាដំបូង នៅលើមូលដ្ឋានសម្ងាត់បំផុត ហើយបន្ទាប់មក អង្គជំនុំជម្រះ សាលាដំបូងនឹងធ្វើការកំណត់មួយអំពីថាតើឯកសារទាំងនោះគួរត្រូវធ្វើចំណាត់ថ្នាក់ជាថ្មីដោយដាក់ថាជាការសម្ងាត់ ឬមួយយ៉ាងណា[35]។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា សូមជូនដំណឹង ដល់អង្គជំនុំជម្រះសាលាដំបូងអំពី កំណត់ហេតុស្តាប់ចម្លើយនានាដែលមាននៅក្នុងឧបសម្ព័ន្ធ ក គឺផ្អែកលើមូលដ្ឋានសម្ងាត់បំផុត។

---

[31] សេចក្តីសំរេចស្តីពីការដាក់បង្ហាញ, កថាខណ្ឌទី២៣(ញ) និងទី២៤។

[32] សេចក្តីសម្រេចលើការដាក់បង្ហាញឯកសារ, កថាខណ្ឌទី២៣(ដ)។

[33] សេចក្តីសម្រេចលើការដាក់បង្ហាញឯកសារ, កថាខណ្ឌទី២៣(ឋ)។

[34] សេចក្តីសម្រេចលើការដាក់បង្ហាញឯកសារ, កថាខណ្ឌទី២៥។

[35] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការជូនដំណឹងអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២", ២៤ មករា ២០១២, ត្រង់ទំព័រទី១។

៧. ដើម្បីឲ្យស្របតាមការកម្រិតនានាខាងលើ សហព្រះរាជអាជ្ញានឹងធ្វើឲ្យបានឆាប់តាមដែលអាចធ្វើទៅបានដើម្បីឲ្យសហមេធាវីនាំមុខ មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន អាចបើកមើលបាននូវសំណៅចម្លងមួយដែលមានដាក់លេខ និងសញ្ញាចំណាំ ដែលរួមបញ្ចូលនូវកំណត់ហេតុស្តាប់ចម្លើយនីមួយៗ។

## II. សំណើ

៨. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. ទទួល និងដាក់បញ្ចូលក្នុងសំណុំរឿង ០០២ នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធ **ក** ដើម្បីអនុវត្តតាមសេចក្តីសម្រេចអនុញ្ញាតរបស់ សចសអ ក្នុងការដាក់បង្ហាញឯកសារលេខ **D193/4**។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |